# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីលក្ខណៈនៃព្រះពុទ្ធគ្រប់ព្រះអង្គ

Website: www.hoksavann.org

ថ្ងៃទី៨ មករា ២០០៥

ព្រះពុទ្ធពុំមែនជាព្រះអាទិទេព ពុំមែនជាទូតរបស់ព្រះអាទិទេព និង ពុំមែនជាអ្នកបែងភាគពីព្រះអាទិទេពឡើយ (The Buddha is neither a god nor a prophet nor the incarnation of a god) ។ ប៉ុន្តែព្រះអង្គ មានជាតិជាមនុស្សជាន់ខ្ពស់ ដែលមានសេចក្តីព្យាយាម ស្វែងរកព្រះធម៌ រហូតសំរេចការត្រាស់ដឹង ដល់ការរំដោះទុក្ខបានជាគ្រូនៃមនុស្សនិងទេវតាទាំងឡាយ (but a supreme human being who, through his own effort, attained to Final Deliverance and Perfect wisdom, and became "the peerless teacher of gods and men") ។ សេចក្តីទុក្ខជាបញ្ហាដែលមនុស្សសត្វត្រូវដោះស្រាយ អ្វីដែលជាហេតុនាំឲ្យកើតទុក្ខ ធម្មជាតិធ្វើជាទីរំលត់ទុក្ខ និងមធ្យោបាយបែបណាជាផ្លូវទៅកាន់ទីរំលត់ទុក្ខ ។ បញ្ហាទាំងនេះ ព្រះពុទ្ធបានរកឃើញតាមការត្រាស់ដឹងរបស់ព្រះអង្គ ។ ការត្រាស់ដឹងរបស់ព្រះអង្គ ពុំមែនដូចការរកឃើញរបស់មនុស្សធម្មតាឡើយ ដូចជាការរកឃើញអ្វីមួយរបស់ក្រុមវិទ្យាសាស្រ្តជាដើម ។ ក៏ខុសគ្នាពីការបញ្ចេញទស្សនៈរបស់ក្រុមទស្សនវិទូបស្ចឹមប្រទេស និងបូព៌ាប្រទេស ។ ការត្រាស់ដឹងរបស់ព្រះពុទ្ធ ជាលទ្ធផលចេញពីការអប់រំព្រះទ័យព្រះអង្គដ៏បរិសុទ្ធ ផុតចាកសេចក្តីសៅហ្មងទាំងអស់តាមរយៈសមថៈវិបស្សនា ចំណែកក្រុមវិទ្យាសាស្រ្តនិងក្រុមទស្សនវិទូ ពុំមានលក្ខណៈដូចព្រះពុទ្ធឡើយ ។ ការរកឃើញអ្វីមួយរបស់ក្រុមវិទ្យាសាស្រ្ត និងការបញ្ចេញទស្សនៈអ្វីមួយដែលហៅថាទស្សនវិជ្ជា របស់ក្រុមទស្សនវិទូ តាមរយៈសម្ភារៈយកមកពិសោធន៍និងតាមការត្រិះរិះពិចារណា ជាគំនិតធម្មតារបស់មនុស្សបុថុជ្ជន ដែលមានលោភៈ ទោសៈ មោហៈ ពុំអាចឃើញការពិតដល់ជំរៅឡើយ មានទស្សនៈខ្លះត្រូវគេយកទៅអនុវត្តធ្វើឲ្យពិភពលោកវិនាស ដូចជាទ្រឹស្តីរបស់កាលម៉ាក មេទ្រឹស្តីកុម្មុយនិស្តជាដើម ។ ដូច្នេះទស្សនវិទូទាំងនោះ ពុំឃើញការពិតទៅតាមពិតជាមាគ៌ានាំសង្គមមនុស្សទៅរកសុខសន្តិភាពឡើយ ។ ចំណែកព្រះពុទ្ធវិញ ព្រះនាមថាអរហំ ព្រះអង្គមានព្រះទ័យបរិសុទ្ធ ផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង មានព្រះបញ្ញាមុតថ្លា ត្រាស់ដឹងនូវធម៌ពិត ដែលហៅថាអរិយសច្ចៈមាន៤ប្រការ (four noble truths) គឺ ទុក្ខសច្ចៈ (suffering) សេចក្តីទុក្ខរបស់មនុស្សសត្វ បានដល់ការកើតមាននៃជាតិគឺជាតិទុក្ខ, សមុទយសច្ចៈ ហេតុនាំឲ្យកើតទុក្ខ (the origin of suffering) បានដល់អវិជ្ជាតណ្ហាសេចក្តីប្រាថ្នារបស់មនុស្សសត្វបិទបាំងដោយអវិជ្ជា (craving, ignorance, aversion), និរោធសច្ចៈ (the cessation of suffering) ការរំលត់ទុក្ខបានដល់ព្រះនិព្វាន, មគ្គសច្ចៈ (the Path leading to the extinction of suffering) ផ្លូវប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ បានដល់មគ្គប្រកបដោយអង្គ៨ (the Eightfold Noble Path) ។ ការត្រាស់ដឹងនូវអរិយសច្ចៈ៤នេះហើយ ទើបព្រះនាមថា សម្មាសម្ពុទ្ធោ ប្រែថាព្រអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ ដែលជាធម៌ដឹកនាំមនុស្សសត្វអ្នកប្រតិបត្តិឲ្យចេញចាកទុក្ខ ។ មគ្គប្រកបដោយអង្គ៨នោះគឺ សម្មាទិដ្ឋិ ការយល់ត្រូវ (Right Understanding), សម្មាសង្កប្បៈ ការត្រិះរិះត្រូវ (Right Thought), សម្មាវាចា វាចាត្រូវ (Right Speech), សម្មាកម្មន្តោ (Right Action) ការងារត្រូវ, សម្មាអាជីវោ (Right Livelihood) ការចិញ្ចឹមជីវិតត្រូវ, សម្មាវាយាមោ (Right Effort) ការព្យាយាមត្រូវ, សម្មាសតិ (Right Mindfulness) ការនឹករលឹកត្រូវ, សម្មាសមាធិ (Right Concentration) ការដំកល់ចិត្តនឹងត្រូវ ។

មគ្គប្រកបដោយអង្គ៨នេះ សូមមិនអធិប្បាយក្នុងទីនេះទេ បើលោកអ្នកស្តាប់អ្នកអានចង់ដឹង សូមរកមើលកន្លែងដទៃទៀតចុះ ។ ដោយសារព្រះពុទ្ធអង្គឃើញសច្ចធម៌៤ប្រការនេះ ដែលគ្មានតាបសឥសីណាសម័យពុទ្ធកាលឃើញមុនព្រះអង្គ ហើយមានតាបសឥសីនិងគ្រប់មនុស្សគ្រប់ឋានៈចូលគោរពធម៌ ព្រះអង្គទើបមានព្រះនាមមួយទៀតថា សត្ថាទេវមនុស្សានំ ប្រែថាព្រះអង្គជាសាស្តាចារ្យនៃមនុស្សនិងទេវតាទាំងឡាយ ។ តាមន័យនេះ គេពុំអាចប្រៀបធៀបព្រះពុទ្ធជាព្រះអរិយបុគ្គលដ៏បរិសុទ្ធមកទស្សនវិទូក្នុងលោក ដែលមានចិត្តសៅហ្មងគ្របដណ្តប់ដោយអវិជ្ជាតណ្ហាបានឡើយ ។ គេពុំត្រូវប្រើពាក្យថា ព្រះពុទ្ធក៏ជាទស្សនវិទូ (Philosopher) មួយព្រះអង្គដែរ ដែលពាក្យប្រៀនប្រដៅរបស់ព្រះអង្គជាទស្សនវិជ្ជា (Philosophy) នោះឡើយ ព្រោះព្រះពុទ្ធបានកំចាត់បង់អវិជ្ជាតណ្ហា និងមិច្ឆាទិដ្ឋិការយល់ខុសហើយ ចំណែកទស្សនវិទូក្នុងលោក ដែលបានបញ្ចេញទស្សនៈ (Point of view) អ្វីមួយស្របទៅតាមសមត្ថភាពធម្មតារបស់ខ្លួន ពុំអាចឃើញការពិតថ្នាក់បរមត្ថវិជ្ជា (Metaphysics) កំចាត់បង់នូវការយល់ខុសដូចជាព្រះពុទ្ធបានឡើយ ។ ប៉ុន្តែបើគេនៅតែទទូចចង់ប្រើពាក្យនេះ ចាំបាច់គេត្រូវតែបញ្ចូលពាក្យញាណមួយទៀត ទៅជាញាណទស្សនវិទូ គឺព្រះពុទ្ធជាញាណទស្សនវិទូ ប្រែថា ព្រះអង្គត្រាស់ដឹងដោយញាណនិងទស្សនៈ គឺប្រាកដឃើញការពិត ។ ក្រុមទស្សនវិទូក្នុងលោកមានមួយភាគមានទស្សនៈត្រូវ ជាលោកិយសច្ចៈ បំរើសេចក្តីសុខដល់សង្គមមនុស្សបានមួយផ្នែក ចំណែកទស្សនវិជ្ជាមួយផ្នែកទៀតបញ្ចេញទស្សនៈខុស ធ្វើឲ្យសង្គមបង្កើតជម្លោះកាប់សម្លាប់គ្នា ដូចជាទ្រឹស្តីកាលម៉ាកជនជាតិអាល្លឺម៉ង់ ដែលលោកឡេនីនជនជាតិរុស្ស៊ីយកទៅអនុវត្តចេញជាកុម្មុយនិស្តជាដើម ។ ចំណែកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ធ្វើឲ្យអ្នកប្រតិបត្តិតាមបានទទួលសុខសន្តិភាព តាំងពីបច្ចុប្បន្ននេះទៅរហូតសំរេចព្រះនិព្វានជាទីរំលត់ទុក្ខ ។

សម័យទំនើបនេះ វិទ្យាសាស្រ្តខាងវិជ្ជាពេទ្យបានចំរើនលូតលាស់យ៉ាងអស្ចារ្យ ទាំងបរិមាណនិងគុណភាព មានសម្ភារៈទំនើបនិងបច្ចេកទេសដ៏ខ្ពស់របស់វេជ្ជបណ្ឌិតក្នុងការព្យាបាលជម្ងឺមនុស្សលោក ។ ប៉ុន្តែទោះបីវិជ្ជាពេទ្យបានចំរើនលូតលាស់យ៉ាងនេះក៏ដោយ ក៏ពុំអាចព្យាបាលមនុស្សឲ្យផុតពីការចាស់ឈឺស្លាប់បានឡើយ ព្រោះការកើតចាស់ឈឺស្លាប់ ជាច្បាប់ធម្មជាតិដែលគេពុំអាចកែប្រែបាន មនុស្សខ្លះពេទ្យព្យាបាលឲ្យបាត់ឈឺនិងឲ្យផុតពីស្លាប់ គ្រាន់តែជាការពន្យាពេលនៃជម្ងឺនិងការស្លាប់ទៅថ្ងៃមុខប៉ុណ្ណោះ ។ បានសេចក្តីថា មនុស្សសត្វកើតមកត្រូវតែស្លាប់ទៅវិញ ។ ដូច្នេះការកើតចាស់ឈឺស្លាប់ ហួសពីសមត្ថភាពនៃវិជ្ជាពេទ្យក្នុងផ្លូវអាណាចក្រដែលអាចកែប្រែបាន ។ ចំណែកព្រះពុទ្ធព្រះបរមគ្រូវិញ ព្រះអង្គមានសមត្ថភាពអាចធ្វើឲ្យមនុស្សសត្វ ចេញផុតពីការកើតចាស់ឈឺស្លាប់ បើគេប្រតិបត្តិតាមធម៌ព្រះអង្គឲ្យបានហ្មត់ចត់ គឺបានសំរេចព្រះនិព្វាន ជាអមតធម៌ ប្រែថាធម៌មិនស្លាប់ ។

ព្រះពុទ្ធសំដែងអំពីព្រះនិព្វានជាទីរំលត់ទុក្ខ ដោយព្រះអង្គសំដែងក្នុងអរិយសច្ចៈទីមួយ គឺទុក្ខសច្ចៈ បានដល់ការមានជាតិប្រកបដោខន្ធ៥

គឺ រូប វេទនា សង្ខារ និង វិញ្ញាណ ដែលប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា ។ ដូច្នេះបញ្ជាក់ថា សេចក្តីទុក្ខកើតឡើងពីការមានជាតិ គឺជាតិទុក្ខ ។ កាលណាមានជាតិ តែងបញ្ជូនទៅរកការចាស់ឈឺស្លាប់ ។ ចំណែកសាសនាដទៃក្រៅពីព្រះពុទ្ធសាសនានិយាយតែស្ថានសួគ៌និងស្ថានព្រហ្ម ។ គេនិយាយថា ស្ថានសួគ៌និងស្ថានព្រហ្ម ជាស្ថានសុខរបស់សាសនាទាំងនោះ ។ បានសេចក្តីថា បើគេជឿព្រះស្មោះត្រង់នឹងព្រះនៃសាសនាទាំងនោះ ព្រះអង្គនឹងឲ្យកើតក្នុងស្ថានសួគ៌និងស្ថានព្រះព្រហ្ម ។ តាមព្រះពុទ្ធសាសនាពោលថា  ស្ថានមនុស្ស ស្ថានសួគ៌ ស្ថានព្រហ្ម ហៅថាភពបី តែងវិលស្លាប់វិលកើតក្នុងសង្សារវដ្ត ។ ភពទាំងបីនេះប្រកបដោយសេចក្តីទុក្ខទោស  ដែលព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើមបានច្រានចោល ហើយបានសំរេចព្រះនិព្វានលែងវិលកើតវិលស្លាប់ ។ ភពទាំងបីនេះ មានសុខខ្លះហៅថាអាមិសសុខ គឺសុខដោយមាយតនៈខាងក្នុងនិងខាងក្រៅប៉ះគ្នា  ក៏កើតជាវេទនាជាសុខជាទុក្ខ  ហើយសុខបែបនេះជាសុខពុំទៀងទាត់ ទីបំផុតត្រូវរលាយបាត់ទៅវិញ ឧទាហរណ៍សុខរបស់មនុស្សដូចអណ្តាតប៉ះរសជាតិអាហារ ដឹងរសជាតិឆ្ងាញ់ពិសារតែត្រឹមអណ្តាតនេះលេបកន្លងផុតពីបំពង់កទៅ ការឆ្ងាញ់ពិសារនោះក៏បាត់ទៅ ។ ស្ថានព្រហ្មនិងស្ថានទេវតាបានសុខជាងមនុស្ស  ប៉ុន្តែអស់បុណ្យក៏ត្រូវច្យុតប្រកបដោយអនិច្ចតាធម៌ដូចស្ថានមនុស្សដែរ  ។  ស្ថានឬភពទាំងបីកើតពីកម្មផលរបស់សត្វដែលបានកសាង  ពុំមែនកើតឡើងពីព្រះជាម្ចាស់អង្គណាមួយកសាងឡើយ ។

## ពាក្យថា<ព្រះ>សំដែងយកបុគ្គលបែបណា

ពាក្យថា<ព្រះ> មកពីពាក្យបាលីថា<វរ:> ប្រែថាប្រសើរ ផ្លាស់<វ> ជា<ព> ឯ<រ>ផ្លាស់ធ្វើជាជើង ទៅជា<ព្រះ> ប្រែថាប្រសើរ។ ពាក្យ<ព្រះ> នេះសំរាប់ដាក់ពីមុខនាមចំពោះបុគ្គលឬវត្ថុ ដែលមានគុណធម៌ឬមានប្រយោជន៍ ដូចពាក្យថាព្រះពុទ្ធព្រះធម៌ព្រះសង្ឃព្រះមាតាព្រះបិតា ឬរហូតប្រើជាមួយធម្មជាតិដែលមានប្រយោជន៍ ដូចពាក្យថា ព្រះអាទិត្យ ព្រះចន្ទ ព្រះធរណី ជាដើម ។ ម៉្យាងទៀ ពាក្យ<ព្រះ>នេះ គេអាចប្រើតែម្នាក់ឯងសំរាប់បុគ្គលដែលគេលើកដម្កើងថាជាកំពូលនៃលោក  គ្មានបុគ្គលណាស្មើដូចជាព្រះពុទ្ធ ព្រះព្រហ្ម ព្រះយេហូវ៉ា ជាព្រះអាទិទេពរបស់ព្រះយេស៊ូ ព្រះអាឡាជាព្រះអាទិទេពរបស់ព្រះមហាម៉ាត់ជាដើម ។ សាសនាដទៃក្រៅពីពុទ្ធសាសនា តែងឲ្យតម្លៃខ្លួនឯងថា ព្រះពិតប្រាកដគឺព្រះបង្កើតលោក ចំណែកព្រះពុទ្ធមិនបង្កើតលោក ពុំមែនជាព្រះពិតប្រាកដទេ គឺគ្រាន់តែជាគ្រូបង្រៀនប៉ុណ្ណោះ ។ គេថាព្រះរបស់គេបង្កើតលោក ប៉ុន្តែគេពុំអាចរកភស្តុតាងត្រង់ណាដែលបញ្ជាក់ថាព្រះសាងលោកឬបង្កើតពិតមែន ។ មួយទៀត គួរឲ្យស្តាយ បើព្រះបង្កើតលោកពិតមែន គួរណាស់តែបង្កើតមនុស្សនិងវត្ថុល្អៗ ដើម្បីឲ្យបានសុខចំរើនដល់សង្គម ពុំគួរបង្កើតមនុស្សមានចិត្តអាក្រក់ ពុំគួរបង្កើតរន្ទះបាញ់ ភ្លើងភ្នំផ្ទុះ រញ្ជួយផែនដី ដូចពេលថ្មីៗនេះ មានរញ្ជួយបាតសមុទ្រហៅថា tsunami ធ្វើឲ្យមនុស្សជាងមួយសែននាក់ត្រូវស្លាប់ របួស៥សែននាក់ និងគ្មានជំរក៥លាន និងសំណង់ផ្សេងៗក៏ត្រូវវិនាស ។ តើព្រឹត្តិការណ៍ទាំងអស់នេះ ព្រះបង្កើតពិតមែន  ឬជាច្បាប់ធម្មជាតិនិងច្បាប់កម្មផល  ដូចវិទ្យាសាស្ត្រនិងព្រះពុទ្ធសាសនាពោលទេ ។ ព្រហ្មញ្ញសាសនាក៏ថាព្រះព្រហ្មបង្កើតលោក  គ្រិស្តសាសនាក៏ថាព្រះអាទិទេពគឺព្រះយេហូវ៉ាបង្កើតលោក  ឥស្លាមសាសនាក៏ថាព្រះអាទិទេពគឺព្រះអាឡ្លាបង្កើតលោក  ចុះបើបង្កើតលោកដូចគ្នាដូច្នេះ  តើព្រះណាពិតប្រាកដដែលបង្កើតលោក  ឬគ្រាន់តែចម្លងតាមគ្នា ព្រោះសាសនាព្រាហ្មកើតមុនសាសនាទាំងពីរ ។ គេចង់ដឹងមួយទៀតថា  តើអ្នកណាបង្កើតព្រះទាំងនោះ  តើព្រះទាំងនោះមានមាតាបិតាមានរូបរាងបែបម៉េចហើយនៅឯណា ។

ចំណែកព្រះពុទ្ធវិញ ព្រះអង្គមានជាតិជាមនុស្ស មានព្រះមាតាបិតា មានទីកន្លែងពិតប្រាកដ  មានរយៈពេលស្វែងរកធម៌  បានត្រាស់ដឹងធម៌ បានសំដែងធម៌ប្រោសសត្វ មានពាក្យប្រៀនប្រដៅរបស់ព្រះអង្គ មានភស្តុតាងពិតប្រាកដ ដែលអ្នកប្រវត្តិសាស្ត្រទទួលស្គាល់ ។ ការឃើញសច្ចធម៌៤ គឺសេចក្តីទុក្ខ ហេតុដែលនាំឲ្យកើតទុក្ខ ទីរំលត់ទុក្ខ និងផ្លូវទៅកាន់ទីរំលត់ទុក្ខ ទើបឈ្មោះថាព្រះអង្គត្រាស់ដឹង គឺត្រាស់ដឹងនៅធម៌ចេញចាកទុក្ខ ទើបព្រះនាមកើតឡើងជាពុទ្ធោ ឬសម្មាសម្ពុទ្ធោ ដែលភាសាខ្មែរថាព្រះពុទ្ធនោះឯង ។ ព្រះនាមរបស់ព្រះពុទ្ធមួយបទថា លោកវិទូ ប្រែថាព្រះអង្គត្រាស់ដឹងនូវលោក ។ បានសេចក្តីថា លោកនិងរចនាសម្ព័ន្ធរបស់លោក កើតមានជាធម្មតា បុំមែនព្រះបង្កើតឡើងទេ ព្រះអង្គគ្រាន់តែឃើញការពិតប៉ុណ្ណោះ ។ លោកដែលព្រះអង្គត្រាស់ដឹងមានបីប្រការ គឺសត្តលោក  បានដល់មនុស្សសត្វមានវិញ្ញាណទាំងអស់  ដែលអន្ទោលទៅមក ស្លាប់កើតទៅភពណាជាតិណាស្របតាមអំពើរបស់ខ្លួន ។ សង្ខារលោកសំដៅយកវត្ថុគ្មានវិញ្ញាណទាំងអស់  ដូចជាព្រះអាទិត្យ  ព្រះច័ន្ទ ផែនដី ព្រៃភ្នំ បឹង ទន្លេ សមុទ្រជាដើ កើតពីការផ្សំធាតុដោយខ្លួនឯង ។ ឱកាសលោកបានដល់រចនាសម្ព័ន្ធនិងទំនាក់ទំនងរវាងវត្ថុធាតុទាំងនោះ ។ ធម្មជាតិទាំងនោះគ្មានអ្នកណាបង្កើតទេ គឺកើតពីសង្ខារ (component, corps composé) គឺធាតុនិងធាតុផ្គុំគ្នាកើតបានជាអ្វីមួយស្របតាមច្បាប់របស់ធម្មជាតិ ឧទាហរណ៍តាមគីមីវិទ្យា $H_2+O=H_2O$ គឺអ៊ីត្រូសែន២បូកនិងអុកស៊ីសែន១ កើតបានជាទឹកជាដើម ។ ព្រះពុទ្ធសំដែងថា អ្វីទាំងអស់កើតពីការផ្សំ (សង្ខារ) រវាងហេតុបច្ច័យដែលវិទ្យាសាស្ត្រថា ការផ្សំបរមាណូធាតុល្អិតជាទីបំផុត  កើតបានជាម៉ូលីគីល  (molicule)  ផ្សំគ្នាច្រើនទៀត ទើបកើតបានជាអង្គធាតុ (organ) ។ ដូច្នេះបញ្ជាក់ថា វត្ថុធាតុពុំមានតួខ្លួនវាពិតទេ គឺកើតពីការផ្សំធាតុដីទឹកភ្លើងខ្យល់នេះឯង ។ ដូចជាសាច់បេះដូងរបស់មនុស្ស  វាមានសាច់វាមានចលនាកំរើកជានិច្ច  បើវាខូចផ្នែកនោះ វាត្រូវឈប់ដើរ ទោះបីអាទិទេពបញ្ជា ក៏វាមិនដើរដែរ ប៉ុន្តែបើសាច់ផ្នែកនោះនៅល្អ វាតែងដើរជាធម្មតា  ទោះបីអាទិទេពមិនបញ្ជាក៏ដោយ ។ ដូច្នេះព្រះពុទ្ធត្រាស់ដឹងនូវច្បាប់ធម្មជាតិ (natural law, loi de la nature) ហើយយកមកប្រកាសប្រាប់មនុស្សសត្វទាំងអស់គ្នា ។ ព្រះអង្គគ្រាន់តែបង្ហាញផ្លូវ (អក្ខាតារោ តថាគតោ = show the way) ឲ្យមនុស្សសត្វដើរដោយខ្លួនឯង  ព្រះអង្គពុំអាចទទួលបាបមនុស្សសត្វបានទេ ព្រោះសេចក្តីបរិសុទ្ធនឹងមិនបរិសុទ្ធដោយខ្លួនឯង អ្នកដទៃពុំអាចញ៉ាំងអ្នកដទៃឲ្យបរិសុទ្ធឬសៅហ្មងបានឡើយ (សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ) ។ ឯសាសន៍ដទៃ ដែលថាសាសនាគេទទួលបាបនោះ ក៏គ្មានទំនាក់ទំនងរវាងហេតុនិងផល យកជាការបានឡើយ ។ អ្នកធ្វើអំពើបាបសៅហ្មងចិត្ត  បើពុំដុសខាត់ចិត្តឲ្យស្អាតដោយខ្លួនឯងទេ  ក៏គ្មានបុគ្គលណាអាចដកចិត្តសៅហ្មងនោះចេញពីចិត្តខ្លួនឯងបានឡើយ  ។  ក៏ដូចជាគ្រូបង្រៀនខំពន្យល់សិស្សនូវមុខវិជ្ជាណាមួយ  បើសិស្សនោះពំយកចិត្តទុកដាក់ស្តាប់ទេ  គ្រូពុំអាចបញ្ចូលវិជ្ជានោះទៅក្នុងខួរក្បាលសិស្សបានឡើយ  ។  ព្រះពុទ្ធសំដែងអំពើបាបនិងបុណ្យ  ប៉ុន្តែព្រះអង្គពុំសំរេចថាអ្នកនេះទទួលផលបាប ឲ្យអ្នកនោះទទួលផលបុណ្យឡើយ គឺបាបបុណ្យឲ្យផលដោយខ្លួនឯងជាស្វ័យប្រវត្តិ អាងដោយពុទ្ធភាសិតថា កម្មផលបែងចែកសត្វឲ្យខ្ពង់ខ្ពស់និងថោកទាប ។

សរុបសេចក្តីមក ព្រះពិតប្រាកដនោះ គឺបុគ្គលដែលរកឃើញអរិយសច្ចធម៌ ដែលជាមាគ៌ាដឹកនាំមនុស្សសត្វ ចេញចាកទុក្ខពិតប្រាកដ គឺព្រះពុទ្ធក្នុងព្រះពុទ្ធសាសនានេះឯង  ។  ព្រះអង្គត្រាស់ដឹងដោយប្រើប្រដាប់

ឆ្លុះ គឺអរិយមគ្គញ្ញាណដោយប្រាជ្ញាដ៏មុតថ្លា ។ ព្រះអង្គជាបុគ្គលឈ្នះលោក ពុំវិលវល់ជាប់ជំពាក់វង្វេងក្នុងលោកឡើយ ។ ដោយមានការអាណិតអាសូរមនុស្សសត្វ ដែលកំពុងមានទុក្ខវិលស្លាប់វិលកើតក្នុងសង្សារវដ្ត ទើបព្រះអង្គសំដែងធម៌ប្រោស ហាក់ដូចជាពន្លឺដែលបំភ្លឺក្នុងទីងងឹត ។ មូលហេតុដែលនាំឲ្យកើតជាតិប្រកបដោយខន្ធ៥ មកពីអវិជ្ជា តណ្ហា ឧបាទាន និងកម្ម ។ ការកើតឡើងនៃខន្ធប្រាំ មានរូបខន្ធជាដើម ជាតួទុក្ខ ព្រោះកាលណាមានជាតិ តែងតែបញ្ជូនទៅរកជរាព្យាធិ និងមរណៈតទៅទៀត ។ ដូច្នេះបើមានព្រះជាម្ចាស់អង្គណាបង្កើតខន្ធ៥ដែលជាតួទុក្ខនេះ ចាត់ទុកជាមូលហេតុបង្កើតទុក្ខដល់មនុស្សសត្វ ដូចអវិជ្ជា តណ្ហា ឧបាទាន កម្មដែរ ។ ព្រះពុទ្ធសាសនាសំដែងថា សេចក្ដីទុក្ខទាំងអស់ កើតមកអំពីការមានជាតិ គឺមានខន្ធ៥នេះឯង ។ ដើម្បីកុំឲ្យមានជាតិជាតួទុក្ខ ត្រូវកំចាត់បង់ហេតុដែលនាំឲ្យកើតទុក្ខ គឺបំបាត់អវិជ្ជា តណ្ហា ឧបាទាន កម្មនេះ កុំឲ្យមានសេសសល់ ។៚

❑